

វិទ្យាស្ថានជាតិអប់រំ

ប្រធានបទសាស្ត្រខ្មែរ

អត្ថន័យពាក្យហ្វូណាន

និងតស្តុតាងមួយចំនួនទៃសហគមន៍ជនជាតិមួយមុនពេលទទួលឥទ្ធិពលឥណ្ឌា

គ្រូខ្មែរ បណ្ឌិត ទី សុផល

ធ្វើបទបង្ហាញដោយ គរុនិស្សិត ប្រថក្តិវិទ្យា

ក្រុមទី១

១.ចាន់ ប៊ុនធិង ២.មី ប៊ូរី

៣.ជួក សារ៉ង ៤.ឈិន ចណ្ឌី ៥.គើប បុរិទ្ធ

ឆ្នាំសិក្សា២០២៣-២០២៤

ឈ្មោះរដ្ឋខ្មែរដំបូង



ប្រភព: បណ្ឌិតសភាចារ្យ ស៊ិន សំណាង (24/01/2024)

តាមព្រះរាជពង្សាវតារភាគតំណាលឆ្នាំ១៨៦៩៖ **នគរគោកធ្លក**ជារដ្ឋប្រជាជនខ្មែរដំបូង ជាព្រះរាជាណាចក្រមួយ ដែលផ្តើមឡើងដោយរាជវង្ស ព្រះថោង និងនាងនាគ នៅឆ្នាំ២៦៧មុនគ.ស.។

នគរគោកធ្លក

តក្កសិលា

ឥន្ទបត្តយសោធរៈ

មហានគរក្រុងកម្ពុជាធិបតី សិរីឥន្ទបត្ត ករុរដ្ឋរាជធានី

ឈ្មោះរដ្ឋខ្មែរដំបូង

- **តាមកំណត់ហេតុចិន** ដែលកត់ត្រាដោយលោកកាំងថៃ និងជូយីង បានហៅខ្មែរពេលនោះថា **ហ្វូណាន** ដែលមានអត្ថិភាពចាប់ពីស.វទី១ ដល់ស.វទី៦ នៃគ.ស.។ បឋមក្សត្រាជាណាចក្រភ្នំ ព្រះនាងលីវ យី និងព្រះបាទហ៊ុនទៀន។



១ អត្ថន័យពាក្យហ្វូណាន

លោក ព្រួម

ជនជាតិខ្មែរ និងព្នង មានដើមកំណើតតែមួយដូចគ្នា។ ខ្មែរពីដើមប្រហែលហៅខ្លួនឯងថា ព្នង ពេលចិនមកដល់ ក៏សរសេរត្រាប់សូរតាម ចេញជាពាក្យ ហ្វូណាន ឬចីយោណាម

លោក ហ្សក សឺដែស

ពន្យល់ថាពាក្យ “ហ្វូណាន” ត្រូវនឹងពាក្យខ្មែរ កុរុងវ៉ឺ ឬស្តេចភ្នំ

គូឡុង ◄កុរុង=ស្តេច ,នៅជ្វា សៃលេន្ទ្រ=ស្តេចភ្នំ

☞ *ហ្វូណាន=នគរភ្នំ*

ធស្សនលោក បណ្ឌិត ទង់ សុធារ៉ា

ជឿថា **ហ្វូណាន** ជាឈ្មោះដែលចិនហៅខ្មែរ ដោយចង់មានន័យថា **អ្នកមានខាងត្បូង** លោកបាននាំយើងឱ្យពិនិត្យមើលបញ្ហា៤យ៉ាងគឺ៖

1. **ការសរសេរចម្លងឡើងវិញជាច្រើនដង** នូវរបាយការណ៍ចិនស្តីពីរឿងរ៉ាវនៅហ្វូណាន វាមិនអាចធានាបានថាអ្នកសរសេរចម្លងឡើងវិញនោះ មិនបានកែអក្ខរាវិរុទ្ធនៃពាក្យដើម "**ហ្វូណាន**" ពីរព្យាង្គនេះបានឡើយ។

2. **បើពិចារណាលើទម្លាប់របស់មនុស្សនៅលើលោកនេះ** តែងហៅជាតិពន្ធផ្សេងក្រៅពីខ្លួន ដោយមិនបាច់គោរពតាមពាក្យដែលជនជាតិដទៃនោះហៅខ្លួនឯងឡើយ ដូចខ្មែរ ហៅ វៀតណាម ថា យួន, ហៅអឺរ៉ុបថា បារាំង...។

3. **យើងសម្គាល់ឃើញថា** ស្ថាននាមភាគច្រើននៅភាគខាងត្បូងនៃប្រទេសចិនតែងតែមានឈ្មោះជាប់នឹងពាក្យ "ខាងត្បូង" ដែលចិនហៅថា **ណាន** ឬ **ណាម** ជានិច្ចដូចជាឈ្មោះ *ណានជីង យូណាន វៀតណាម*ជាដើម។

4. **វៀតណាមទម្លាប់តាំងពីបុរាណមកហៅខ្មែរថា "ការ មៀន"** មានន័យថា "អ្នកមានខ្ពង់ខ្ពស់"

សន្ធិដ្ឋាន



ដូច្នេះពាក្យទី១ ដែលចិនបានសរសេរដំបូងគួតែជាពាក្យ៖

☞ "**ហ្វូ**" មានន័យថា **សម្បូរទ្រព្យសម្បត្តិ ឬអ្នកមាន** *និងពាក្យ*

☞ "**ណាន ឬណាម**" មានន័យថា **ខាងត្បូង**។

➲រួមមកពាក្យ "**ហ្វូណាន ឬហ្វូណាម**" មានន័យថា *ប្រទេសអ្នកមានខាងត្បូង ឬមហាសាលខាងត្បូង*។

๒


តស្តុតាងមួយចំនួនដែលសហគមន៍ជនជាតិមួយមុនពេលទទួលឥទ្ធិពលឥណ្ឌា

សហគមន៍

- ការទៅជាមួយ, ដំណើរជាមួយគ្នា
- ប្រជុំភូមិឬតំបន់អ្នកស្រុកប្រកបមុខរបរចូលគ្នា,...
- ក្រុមមនុស្សដែលរស់នៅកន្លែងណាមួយក្នុងប្រទេសឬតំបន់ ហើយមានផលប្រយោជន៍រួមគ្នាលើផ្នែកសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ជាដើម។

❑ **ការស្រាវជ្រាវបុរាណវិទ្យាមានមនុស្សមករស់នៅតាំងទីលំនៅនៅកម្ពុជាតាំងពី៦,០០០ឆ្នាំមកហើយ**

- **សង្គម** មនុស្សចេះរៀបចំការរស់នៅជាសហគមន៍ “ភូមិមូល” រស់នៅតាមវាលទំនាប ក្បែរប្រភពទឹក សង់ផ្ទះផុតពីដី
- **នៅក្នុងយុគថ្មីរំលីងគិតចាប់ពី៣៥០០ឆ្នាំមុនគ.ស** មនុស្សលែងរស់នៅក្នុងល្អាងភ្នំ តែគេយកល្អាងភ្នំជាកន្លែងបញ្ចុះសព និងរស់នៅតាមតំបន់ខ្ពង់រាបដីក្រហម និងតំបន់ទំនាប គេបានរកឃើញនៅខេត្តត្បូងឃ្មុំគឺស្ថានីយភូមិមូល និងស្ថានីយល្អាងស្ពានៅបាត់ដំបងនិងស្ថានីយសំរោងសែន ។



គំនូរនៃភូមិមូលនៅសារមន្ទីរជាតិភ្នំពេញ
ប្រភព: https://kampongchamprovince.wordpress.com/

- **ជំនឿ** មនុស្សមានជំនឿលើជីវៈ ចលនិយម វត្ថុ សត្វ ធម្មជាតិ ព្រៃភ្នំ ហើយក៏បន្តមកដល់បច្ចុប្បន្ន
- **វប្បធម៌** មានប្រពៃណីការកប់សព ដាក់ដង្វាយ កាក់មាស និងគ្រឿងអលង្កា.. សម្លៀកបំពាក់។



រណ្តៅសពនៅយុគថ្មរំលីង រកឃើញនៅភ្នំល្អាង

- **សេដ្ឋកិច្ច** មនុស្សរស់នៅដោយការធ្វើកសិកម្ម ចេះពីរបៀបបាចទឹកបញ្ចូលស្រែ ចេះធ្វើសប្បកម្មផលិតសម្ភារប្រើប្រាស់ចម្រាប់ជីវភាពប្រចាំថ្ងៃ
- **យុគលោហៈ (ឆ្នាំ ៨០០មុនគ.ស.)** មនុស្សមករស់នៅតាមតំបន់វាលទំនាប ក្បែរមាត់ទន្លេ ស្ទឹង បឹងបួរ ដែលតំបន់ទាំងនោះសម្បូរត្រីដីមានជីវជាតិអំណោយផលល្អដល់កសិកម្ម និងងាយស្រួលក្នុងការធ្វើដំណើរតាមផ្លូវទឹក។ ការធ្វើជំនួញនិងការផ្លាស់ប្តូរវប្បធម៌ពីទីឆ្ងាយ បានផ្តើមរីកលូតលាស់យ៉ាងឆាប់រហ័ស។ បុរាណវិទូបានរកឃើញសម្ភារៈប្រើប្រាស់មួយចំនួននៅសៀមរាប បន្ទាយមានជ័យ ព្រៃវែង ត្បូងឃ្មុំ និងស្ថានីយ៍ដទៃទៀត ។



ប្រជាជននៅអាស៊ីអាគ្នេយ៍ចេះធ្វើកសិកម្មតាំងប្រហែល ៥៥០០មុនគ.ស.





- **នយោបាយ** មានមេកន្ត្រាញ្ជាអ្នកមើលការខុសត្រូវក្នុងសហគមន៍ ព្រះនាងលីវ យី ជាបឋមក្សត្រខ្មែរជាអ្នកដឹកនាំរដ្ឋនៅរាជាណាចក្រភ្នំ
- **តាមរយៈភស្តុតាងផ្នែកប្រវត្តិសាស្ត្រ** របស់រាជទូតចិនដែលកត់ត្រាពីនគរខ្មែរនៅស.វទី៣ ថាមានស្តេចមួយអង្គមានកំណើតជាជនបរទេសឈ្មោះថា ព្រះបាទហ៊ុនទៀន ធ្វើដំណើរតាមសំពៅមកដែនដីហ្វូណាន ហើយច្បាំងជាមួយហ្វូណានឬនគរភ្នំ លុះច្បាំងឈ្នះក៏រៀបអភិសេកជាមួយស្តេចស្រីដែលគ្រប់គ្រងនៅនគរភ្នំនេះ ហើយបានប្តូរបបគ្រប់គ្រងពីមាតាធិបតេយ្យទៅសង្គមបិតាធិបតេយ្យគ្រប់គ្រងដោយស្តេចប្រុស ។

សេចក្តីសន្និដ្ឋាន

- បច្ចុប្បន្ននេះពាក្យ ហ្វូណាន ត្រូវបានអ្នកសិក្សាទូទៅយល់ស្របគ្នាថា ជាឈ្មោះដែលចិនបានហៅរដ្ឋខ្មែរនៅដើមគ.ស. ដោយចង់សំដៅលើតំបន់ឬរដ្ឋដែលសម្បូរធនធានធម្មជាតិនៅភាគខាងត្បូងនៃប្រទេសចិន។
- តាមការបង្ហាញពីបុរាណវិទ្យា ខ្មែរយើងរស់នៅជាសហគមន៍រួចទៅមុនពេលមានវត្តមានឥណ្ឌាមកដល់ ព្រោះយើងមានទំនៀមទម្លាប់ប្រពៃណី វប្បធម៌ជារបស់ខ្លួនរួចមកហើយ។

ឯកសារយោង

១.បណ្ឌិតសភាចារ្យ ស៊ន សំណាង វេទិការប្រវត្តិវិទ្យាលើកទី៨៨ *"តើកោះគោកធ្លកលាតសន្ធឹងពីណាដល់ណាតាមដែនីរបស់បារាំង"* **ថ្ងៃពុធទី២៤ មករា ២០២៤**

២.រាជាណាចក្រកំ្ពុ និងនគរគោកធ្លក *បច្ចេកសព្ទរបស់គណៈកម្មការបច្ចេកទេសប្រវត្តិវិទ្យា* ជាក់ជូនក្រុមប្រឹក្សាជាតិភាសាខ្មែរ ដែលត្រូវបានអនុម័តនាថ្ងៃទី**៩ ខែមករា ឆ្នាំ២០២៤**

៣.បណ្ឌិត វង់ សុធារ៉ា និងលោក ណុប សុខា *ប្រវត្តិសាស្ត្រខ្មែរ* **ឆ្នាំ២០១៥** ភ្នំពេញ

៤.លោក ត្រឹង ងា *ប្រវត្តិសាស្ត្រខ្មែរ ភាគទី១* ឆ្នាំ១៩៧៣

៥.ក្រសួងអប់រំ យុវជន និងកីឡា *ប្រវត្តិវិទ្យា ថ្នាក់ទី៤ ខ្មែរ និងដំណើរឆ្ពោះទៅសម័យអង្គរដ៏រុងរឿង* **ឆ្នាំ២០២១**

៦.បណ្ឌិត ជា មុនីឫទ្ធិ *ទស្សនវិជ្ជាខ្មែរនាសម័យហ្វូណាន* ឆ្នាំ២០១៥

៧.ក្រសួងសិក្សាធិការ ពង្សាវតារនៃប្រទេសកម្ពុជា **ឆ្នាំ១៩៥២**

៨.លោក ឆ័ត្រា ប្រេមឫឌី *ល្បងសិក្សាពីនគរគោកធ្លក* **ឆ្នាំ១៩៩៥**